

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

CIAS 29

ការរាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុ នៅក្នុងសេដ្ឋកិច្ច មានអតិផរណាហួសហេតុ

Financial Reporting in Hyperinflationary Economies

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

អារម្ភកថា

ដោយសារនយោបាយ "**ឈ្នះ-ឈ្នះ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបានន្ូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទ្ូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងន្ូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ន្ូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**", "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**", "**យុទ្ធសាស្ត្រត្រីកោណ**", "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**" និង "**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**" ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និង**ក្រុមប្រឹក្សាជាតិគណនេយ្យ** ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតន្ូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ជាត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី "**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា**" ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបានន្ូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ពន្ធ៍ទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ពន្ធ៍នៃ “**យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីសំយកហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**” របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **អ៊ឹ តាយ៉ី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

អារម្ភកថា

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**"។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី "គណនេយ្យ សហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ" នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន" *ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* " និង *"ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម"* ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.ស-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍនភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥

រដ្ឋលេខាធិការ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា

ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ

ង៉ី ស៊ាយ៉ី

១ ស្តង់ដានេះត្រូវប្រើចំពោះរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់អង្គភាពណាមួយ ដែលរូបិយវត្ថុមុខងារគឺជារូបិយវត្ថុ នៃសេដ្ឋកិច្ចមានអតិផរណាហួសហេតុ

២ នៅក្នុងសេដ្ឋកិច្ចមានអតិផរណាហួសហេតុ ការរាយការណ៍នៃលទ្ធផលពីកិច្ចប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុនៅក្នុងរូបិយវត្ថុក្នុងស្រុក ដោយពុំមានការបង្ហាញឡើងវិញ មិនមានប្រយោជន៍ទេ។ ប្រាក់បាត់បង់អំណាចទិញតាមអត្រាមួយដែលការប្រៀបធៀបនៃទឹកប្រាក់ពីប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងទៀត ដែលបានកើតនៅពេលខុសគ្នា ទោះបីជាស្ថិតនៅក្នុងការិយបរិច្ឆេទគណនេយ្យដូចគ្នា នាំឱ្យមានការយល់ច្រឡំ ។

៣ ស្តង់ដានេះ មិនបង្កើតឡើងនូវអត្រាដាច់ខាត ដែលអតិផរណាហួសហេតុត្រូវបានចាត់ទុកថាកើតឡើងនោះទេ។ វាគឺជាបញ្ហាមួយនៃការវិនិច្ឆ័យ នៅពេលដែលការបង្ហាញឡើងវិញ នៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមស្តង់ដានេះមានចាំបាច់នោះ ។ អតិផរណាហួសហេតុត្រូវបានបង្ហាញដោយចរិតលក្ខណៈនៃបរិស្ថានសេដ្ឋកិច្ចរបស់ប្រទេសមួយ ដែលរួមបញ្ចូល ប៉ុន្តែមិនត្រូវបានកម្រិតត្រឹម មានដូចក្រោម:

(ក) ប្រជាពលរដ្ឋទូទៅចូលចិត្តរក្សាទុកទ្រព្យសម្បត្តិជាទ្រព្យសកម្មមិនមែនរូបិយវត្ថុ ឬជារូបិយប័ណ្ណបរទេសដែលមានស្ថេរភាព ។

ទឹកប្រាក់នៃរូបិយវត្ថុក្នុងស្រុក ដែលរក្សាទុកគឺត្រូវបានវិនិយោគ ភ្លាមដើម្បីរក្សាអំណាចទិញ ។

(ខ) ប្រជាពលរដ្ឋទូទៅចាត់ទុកទឹកប្រាក់រូបិយវត្ថុមិនស្ថិត នៅក្នុង លក្ខខណ្ឌនៃរូបិយវត្ថុក្នុងស្រុក ប៉ុន្តែស្ថិតក្នុងលក្ខខណ្ឌ នៃ រូបិយប័ណ្ណ បរទេសដែលមានស្ថេរភាព ។ តម្លៃត្រូវបាន ដាក់កំណត់នៅក្នុងរូបិយប័ណ្ណនោះ ។

(គ) ការលក់និងការទិញដោយជំពាក់កើតមានឡើងតាមតម្លៃ ដែល តបស្នង ចំពោះការបាត់បង់អំណាចទិញ ដែលបានរំពឹងទុកក្នុង កំឡុងការិយបរិច្ឆេទឥណទាន ទោះបីជាការិយបរិច្ឆេទនោះខ្លី ។

(ឃ) អត្រាការប្រាក់ ប្រាក់ឈ្នួល និងតម្លៃត្រូវបានភ្ជាប់ទៅសន្ទស្សន៍ តម្លៃ និង

(ង) អត្រាអតិផរណាបូកបន្តលើរយៈពេល បីឆ្នាំ បានខិតជិត ឬលើស ពី១០០%។

៤ វាជាការល្អ ដែលអង្គភាពទាំងអស់រាយការណ៍ជារូបិយប័ណ្ណ នៃសេដ្ឋកិច្ច អតិផរណាហួសហេតុដូចគ្នាប្រើប្រាស់ ស្តង់ដានេះពីកាលបរិច្ឆេទដូចគ្នា ទោះបីជាយ៉ាងណាក៏ដោយ ស្តង់ដានេះអនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ របស់អង្គភាព ណាមួយ ពីដើមដំបូង នៃការិយបរិច្ឆេទរាយការណ៍ ដែល អង្គភាពកំណត់បានពីការកើតមានឡើង នៃអតិផរណាហួសហេតុនៅក្នុង ប្រទេសជារូបិយប័ណ្ណរបស់គេ ដែលអង្គភាពរាយការណ៍។

ការបង្ហាញឡើងវិញនៃរបាយការណ៍ហិរញ្ញវត្ថុ

៥ តម្លៃប្រែប្រួលលើរយៈពេលមួយដែលជាលទ្ធផលនៃអំណាចនយោបាយ សេដ្ឋកិច្ច និងសង្គមទូទៅឬជាក់លាក់ផ្សេងទៀត។ អំណាចជាក់លាក់ ដូចជាការប្រែប្រួលការផ្គត់ផ្គង់ និងការប្រែប្រួលតម្រូវការនៃបច្ចេកវិជ្ជាអាចបង្ក ឱ្យមានតម្លៃរមួយដើម្បីបង្កើន ឬបន្ថយខាងខ្លាំង និងមានភាពឯករាជ្យទៅ វិញទៅមក។ លើសពីនេះ អំណាចទូទៅអាចនាំឱ្យមានការផ្លាស់ប្តូរកម្រិត តម្លៃទូទៅ ដូច្នេះ នៅក្នុងអំណាយទិញជាទូទៅនៃប្រាក់ ។

៦ អង្គភាពទាំងឡាយ ដែលរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណ-នេយ្យថ្លៃដើមប្រវត្តិសាស្ត្រធ្វើដូច្នេះ ដោយមិនគោរពចំពោះការផ្លាស់ប្តូរនៅ ក្នុងកម្រិតទូទៅនៃតម្លៃ ឬចំពោះការកើនឡើងតម្លៃជាក់លាក់នៃទ្រព្យសកម្ម ឬបំណុលដែលទទួលស្គាល់។ ការលើកលែងចំពោះករណីនេះ គឺជាទ្រព្យ សកម្ម និងបំណុលទាំងឡាយ ដែលអង្គភាពត្រូវបានតម្រូវ ឬជ្រើសរើស ដើម្បីវាស់វែងតាមតម្លៃសមស្រប។ ឧទាហរណ៍ ទ្រព្យសកម្ម រោងចក្រ និង បរិក្ខារអាចត្រូវបានវាយតម្លៃឡើងវិញតាមតម្លៃសមស្រប និងទ្រព្យសកម្ម ជីវសាស្ត្រជាទូទៅ ត្រូវបានតម្រូវឱ្យវាស់វែង តាមតម្លៃសមស្រប ។ ប៉ុន្តែ អង្គភាព ខ្លះបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលផ្អែក លើវិធីសាស្ត្រថ្លៃដើម បច្ចុប្បន្នដែលឆ្លុះបញ្ចាំងពីផលប៉ះពាល់នៅក្នុងតម្លៃជាក់លាក់នៃទ្រព្យ សកម្មដែលបានកាន់កាប់។

៧ នៅក្នុងសេដ្ឋកិច្ចដែលមានអតិផរណាខ្ពស់ហួសហេតុ ថាតើរបាយការណ៍ ទាំងនោះ ត្រូវបានរៀបចំដោយផ្អែកលើវិធីសាស្ត្រថ្លៃដើម ឬវិធីសាស្ត្រ ថ្លៃដើមបច្ចុប្បន្ន របាយការណ៍ហិរញ្ញវត្ថុមានប្រយោជន៍តែប្រសិនបើរបាយ

ការណ៍ហិរញ្ញវត្ថុទាំងនោះ ត្រូវបានបង្ហាញក្នុងលក្ខខណ្ឌនៃឯកត្តាវាស់វែងបច្ចុប្បន្ន តាមការិយបរិច្ឆេទរាយការណ៍ ។ ជាលទ្ធផលស្តង់ដានេះអនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព ដែលរាយការណ៍ជារូបិយប័ណ្ណនៃសេដ្ឋកិច្ចដែលមានអតិផរណាហួសហេតុ ។ ការបង្ហាញនៃព័ត៌មាន ដែលបានតម្រូវដោយស្តង់ដានេះ ជាព័ត៌មានបន្ថែម ដើម្បីយល់ពីរបាយការណ៍ហិរញ្ញវត្ថុ មិនត្រូវបានអនុញ្ញាតិ ។ លើសពីនេះទៅទៀត ការបង្ហាញដាច់ដោយឡែកនៃរបាយការណ៍ហិរញ្ញវត្ថុមុនការបង្ហាញឡើងវិញមិនត្រូវបានលើកទឹកចិត្តទេ ។

៨ របាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពមួយដែលរូបិយប័ណ្ណមុខងាររបស់គេគឺរូបិយប័ណ្ណនៃសេដ្ឋកិច្ចដែមានអតិផរណាខ្ពស់ហួសហេតុ ថាតើរបាយការណ៍ទាំងនោះផ្អែកលើវិធីសាស្ត្រថ្លៃដើមប្រវត្តិសាស្ត្រឬ វិធីសាស្ត្រថ្លៃដើមបច្ចុប្បន្ន ត្រូវបានបង្ហាញនៅក្នុលក្ខខណ្ឌនៃឯកត្តាវាស់វែងបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍ ។ តួរលេខដែលស្របគ្នាសម្រាប់ការិយបរិច្ឆេទមុន ដែលបានតម្រូវដោយ ស.គ.អ.ក ១ *ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* (ដូចបានកែប្រែនៅក្នុងឆ្នាំ២០០៧) និងព័ត៌មានណាមួយដែលទាក់ទិននឹងការិយបរិច្ឆេទមុនៗ ក៏ត្រូវបានបង្ហាញផងដែរនៅក្នុងលក្ខខណ្ឌឯកត្តាវាស់វែងបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍ការ ។ សម្រាប់គោលបំណងនៃការបង្ហាញទឹកប្រាក់ប្រៀបធៀបជារូបិយវត្ថុបង្ហាញផ្សេងទៀត កថាខណ្ឌ ៤២(ខ) និង ៤៣ នៃ ស.គ.អ.ក ២១ *ផលប៉ះពាល់នៃការផ្លាស់ប្តូរអត្រាប្តូរប្រាក់បរទេស* អនុវត្ត។

៩ ចំណេញ ឬខាតនៅស្ថានភាពរូបិយវត្ថុពិតត្រូវបានបញ្ចូលនៅក្នុងផល

ចំណេញ ឬខាត និង ត្រូវបានលាតត្រដាងបង្ហាញដាច់ដោយឡែក។

១០ ការបង្ហាញឡើងវិញនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដា នេះ តម្រូវឱ្យមានការអនុវត្ត នៃនីតិវិធីជាក់លាក់ ក៏ដូចជាការវិនិច្ឆ័យ។ ការអនុវត្ត ដែលមានសង្គតិភាពនៃនីតិវិធីទាំងនេះ និងការវិនិច្ឆ័យពីគ្រាមួយទៅគ្រាមួយទៀត គឺមានសារៈសំខាន់ច្រើនជាងភាពត្រឹមត្រូវច្បាស់លាស់នៃទឹកប្រាក់កើតឡើងដែលបានរួម បញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញឡើងវិញ។

របាយការណ៍ហិរញ្ញវត្ថុផ្អែកលើថ្លៃដើមប្រវត្តិសាស្ត្រ

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

១១ ទឹកប្រាក់នៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដែលមិនទាន់បានបង្ហាញនៅក្នុងលក្ខខណ្ឌនៃឯកតាវាស់វែង បច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍ ត្រូវបានបង្ហាញដោយការអនុវត្តសន្ទស្សន៍តម្លៃទូទៅ។

១២ ធាតុរូបិយវត្ថុ ត្រូវបានបង្ហាញឡើងវិញ ពីព្រោះធាតុទាំងនោះត្រូវបានបង្ហាញរួចហើយក្នុងលក្ខខណ្ឌឯកតា រូបិយវត្ថុបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍។ ធាតុរូបិយវត្ថុគឺជាប្រាក់ដែលត្រូវបានកាន់កាប់ និងធាតុនោះនឹងត្រូវបានទទួល ឬ សងជាប្រាក់ ។

១៣ ទ្រព្យសកម្ម និងបំណុលដែលចងដោយកិច្ចព្រមព្រៀង ចំពោះការផ្លាស់ប្តូរតម្លៃ ដូចជា សន្ទស្សន៍ដែលទាក់ ទងនឹងសញ្ញាបណ្ណ និងកម្ចី ត្រូវបានកែសម្រួលដោយអនុលោម តាមកិច្ចព្រមព្រៀង ដើម្បីអះអាងពីទឹកប្រាក់ដែលនៅជំពាក់នៅចុងការិយបរិច្ឆេទរាយការណ៍។ ធាតុទាំងនេះ ត្រូវបាន

កត់ត្រាតាមទឹកប្រាក់ដែលបានកែសម្រួលរួចនេះនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុបង្ហាញឡើងវិញ ។

១៤ ទ្រព្យសកម្ម និងបំណុលទាំងអស់ផ្សេងទៀតគឺមិនមែនរូបិយវត្ថុទេ ។ ធាតុមិនមែនរូបិយវត្ថុមួយចំនួនទៀតត្រូវបាន កត់ត្រាតាមទឹកប្រាក់បច្ចុប្បន្ន នៅចុងការិយបរិច្ឆេទរាយការណ៍ ដូចជាតម្លៃទទួលស្គាល់ពិត និងតម្លៃសមស្រប ដូចនេះធាតុទាំងនោះមិនត្រូវបានបង្ហាញឡើងវិញទេ ។ ទ្រព្យសកម្ម និងបំណុលមិនមែនរូបិយវត្ថុទាំងអស់ផ្សេងទៀតត្រូវបានបង្ហាញឡើងវិញ ។

១៥ ធាតុមិនមែនហិរញ្ញវត្ថុភាគច្រើនត្រូវបានកត់ត្រាតាមថ្លៃដើម ឬថ្លៃដើមដកវិលស់ ដូច្នេះ ពួកគេត្រូវបានបង្ហាញតាមទឹកប្រាក់បច្ចុប្បន្ន នៅថ្ងៃទិញរបស់គេ។ ថ្លៃដើមបង្ហាញឡើងវិញ ឬថ្លៃដើមដកវិលស់ នៃធាតុមួយៗ ត្រូវបានគណនាដោយការប្រើថ្លៃដើមប្រវត្តិសាស្ត្រ និងតម្លៃបូកបន្ត នូវការប្រែប្រួលសន្ទស្សន៍តម្លៃ ទូទៅពីថ្ងៃទិញទៅចុងការិយបរិច្ឆេទរាយការណ៍។ ឧទាហរណ៍ ទ្រព្យ រោងចក្រ និងបរិក្ខារ សន្និធិជាវត្ថុធាតុដើម និងទំនិញ មូលនិធិពាណិជ្ជកម្ម ប្រកាសនីយបត្រស្ថាកសញ្ញាពាណិជ្ជកម្ម និងទ្រព្យសកម្មស្រដៀងផ្សេងទៀតត្រូវបានបង្ហាញឡើងវិញចាប់ពីថ្ងៃនៃការ ទិញរបស់ពួកគេ ។ សន្និធិនៃទំនិញពាក់កណ្តាលសម្រេច និងសម្រេចរួចត្រូវបានបង្ហាញឡើងវិញចាប់ពីថ្ងៃទីដែលថ្លៃដើមនៃការទិញ និងថ្លៃដើមនៃការបំលែងបានកើតឡើង ។

១៦ ឯកសារលម្អិតអំពីថ្ងៃទិញធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារមិនអាចរកបាន ឬមិនអាចប្រើសម្រាប់ការប៉ាន់ស្មាន។នៅក្នុងកាលៈទេសៈដ៏កម្រ

ទាំងនេះវាអាចមានភាពចាំបាច់នៅក្នុងការិយបរិច្ឆេទដំបូង នៃការអនុវត្ត ស្តង់ដានេះ ដើម្បីប្រើប្រាស់ការវាយតម្លៃឯករាជ្យ តាមបែបវិជ្ជាជីវៈនៃ តម្លៃ នៃធាតុជាមូលដ្ឋានសម្រាប់ ការវាយតម្លៃរបស់គេ ។

១៧ សន្មស្សន៍តម្លៃទូទៅមិនអាចរកបាន សម្រាប់ការិយបរិច្ឆេទដែលការបង្ហាញ ឡើងវិញនៃទ្រព្យសកម្ម រោងចក្រ និងបរិក្ខារត្រូវបានតម្រូវ ដោយស្តង់ដា នេះ។ នៅក្នុងកាល:ទេស:ទាំងនេះ វាអាចមានភាពចាំបាច់ដើម្បីប្រើ ការប៉ាន់ស្មានដែលផ្អែកលើ ជាឧទាហរណ៍ ការប្រៃប្រួលអត្រាប្តូរប្រាក់ រវាងរូបិយវត្ថុមុខងារ និងរូបិយប័ណ្ណបរទេស ដែលមានស្ថេរភាពទាក់ទិន ។

១៨ ធាតុមិនមែនរូបិយវត្ថុខ្លះត្រូវបានកត់ត្រាតាមទឹកប្រាក់បច្ចុប្បន្ននៅថ្ងៃនោះ ជាជាងថ្ងៃទិញ ឬថ្ងៃនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឧទាហរណ៍ ទ្រព្យ រោងចក្រ និងបរិក្ខារដែលត្រូវបានវាយតម្លៃឡើងវិញនៅថ្ងៃមុនខ្លះ ។ នៅ ក្នុងករណីទាំងនេះ តម្លៃយោងត្រូវបានបង្ហាញឡើងវិញ ចាប់ពីថ្ងៃនៃថ្ងៃ វាយតម្លៃឡើងវិញ ។

១៩ ទឹកប្រាក់បង្ហាញឡើងវិញ នៃធាតុមិនមែនរូបិយវត្ថុ ត្រូវបានកាត់បន្ថយ ដោយអនុលោមតាម ស.រ.ហ.អ.ក សមស្រប នៅពេលទឹកប្រាក់នោះ លើសតម្លៃទទួលបានមកវិញ។ ឧទាហរណ៍ ទឹកប្រាក់បង្ហាញឡើងវិញនៃ ទ្រព្យ រោងចក្រ បរិក្ខារ មូលនិធិពាណិជ្ជកម្ម ប្រកាសនីយបត្រ ស្ថាកសញ្ញា ពាណិជ្ជកម្មត្រូវបានកាត់បន្ថយមក ត្រឹមទឹកប្រាក់ទទួលបានមកវិញ និង ទឹកប្រាក់បង្ហាញឡើងវិញនៃសន្និធិត្រូវបានកាត់បន្ថយមកត្រឹមតម្លៃទទួល ស្គាល់ពិត ។

២០ ក្រុមហ៊ុនរងការវិនិយោគ ដែលត្រូវបានធ្វើគណនេយ្យកម្ម តាមវិធីសាស្ត្រ

មូលធនអាចរាយការណ៍ ជារូបិយវត្ថុនៃសេដ្ឋកិច្ចអតិផរណាហួសហេតុ ។ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍លទ្ធផលលម្អិតរបស់ក្រុមហ៊ុនរងការទទួលវិនិយោគត្រូវបានបង្ហាញឡើងវិញ ដោយអនុលោមតាមស្តង់ដានេះ ដើម្បីគណនាចំណែករបស់អ្នកវិនិយោគនៃទ្រព្យសកម្មពិត និងផលចំណេញ ឬខាត។ នៅពេលដែលរបាយការណ៍ហិរញ្ញវត្ថុបង្ហាញឡើងវិញនៃក្រុមហ៊ុនរងការវិនិយោគត្រូវបានបង្ហាញជារូបិយប័ណ្ណបរទេស របាយការណ៍ហិរញ្ញវត្ថុត្រូវ បានប្រែសម្រួលតាមអត្រាបិទបញ្ជី ។

២១ ឥទ្ធិពលនៃអតិផរណាជាទូទៅ ត្រូវបានទទួលស្គាល់នៅក្នុងបន្ទុកលើប្រាក់កម្ចី ។ វាមិនសមស្របទេដើម្បី បង្ហាញឡើងវិញនូវចំណាយដើមទុន ដែលបានធ្វើហិរញ្ញប្បទានដោយកម្ចីនិងដើម្បីធ្វើមូលធនកម្មផ្នែកនោះ នៃបន្ទុកលើប្រាក់កម្ចី ដែលតបស្នងអតិផរណា ក្នុងកំឡុងការិយបរិច្ឆេទដូចគ្នា ។ ផ្នែកនៃបន្ទុកលើប្រាក់កម្ចីនេះ ត្រូវបានទទួលស្គាល់ជាចំណាយ នៅក្នុងការិយបរិច្ឆេទដែលថ្លៃដើមទាំងនោះកើតឡើង ។

២២ អង្គភាពមួយ អាចទិញទ្រព្យសកម្ម ក្រោមការកិច្ចរៀបចំដែលអនុញ្ញាតិឱ្យអង្គភាពធ្វើការពន្យាការទូទាត់ ដោយមិនកើតឡើងនូវចំណាយការប្រាក់ជាក់លាក់នោះទេ។ ពេលណាដែលមិនអាចអនុវត្តបានដើម្បីដាក់បន្ទុកទឹកប្រាក់នៃការប្រាក់ ទ្រព្យសកម្មបែបនេះត្រូវបានលាតត្រដាងឡើងវិញចាប់ពីថ្ងៃទូទាត់ និងមិនមែនថ្ងៃទិញទេ។

២៣ [លុបចោល]

២៤ នៅដើមគ្រាដំបូង នៃការអនុវត្តនៃស្តង់ដានេះ សមាសធាតុនៃមូលធនរបស់ម្ចាស់ លើកលែងតែប្រាក់ចំណេញរក្សាទុក និងអតិរេកពីការវាយ

តម្លៃណាមួយ ត្រូវបានបង្ហាញឡើងវិញដោយប្រើសន្ទស្សន៍តម្លៃទូទៅចាប់ពីថ្ងៃដែលសមាសធាតុ ត្រូវបានដាក់បញ្ចូលដើមទុន ឬក៏បានកើតឡើង។ អតិរេកពីការវាយតម្លៃណា មួយដែលបានកើតឡើងនៅក្នុងគ្រាមុនត្រូវបានលុបចោល។ ប្រាក់ចំណេញរក្សាទុកដែលបង្ហាញឡើងវិញត្រូវបានទទួល មកពីរាល់ទឹកប្រាក់ផ្សេងទៀតនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ បង្ហាញឡើងវិញ ។

២៥ នៅចុងគ្រាដំបូង និងនៅក្នុងគ្រាបន្តបន្ទាប់ សមាសធាតុនៃមូលធនរបស់ម្ចាស់ដោយប្រើសន្ទស្សន៍តម្លៃទូទៅចាប់ពីដើមគ្រា ឬថ្ងៃនៃការដាក់ដើមទុនប្រសិនបើជានៅពេលក្រោយ។ការប្រែប្រួលសម្រាប់គ្រានៅក្នុងមូលធនរបស់ម្ចាស់ត្រូវបានលាតត្រដាងដោយអនុលោមតាម ស.គ.អ.ក ១ ។

របាយការណ៍លទ្ធផលលម្អិត

២៦ ស្តង់ដានេះ តម្រូវថាគ្រប់ធាតុនៅក្នុងរបាយការណ៍លទ្ធផលលម្អិត ត្រូវបានបង្ហាញនៅក្នុងលក្ខខណ្ឌនៃឯកតា រាស់វែងបច្ចុប្បន្ននៅចុងការិយ-បរិច្ឆេទរាយការណ៍។ ដូច្នេះទឹកប្រាក់ទាំងអស់ត្រូវការបង្ហាញ ឡើងវិញដោយប្រើការប្រែប្រួល សន្ទស្សន៍តម្លៃទូទៅចាប់ពីថ្ងៃដែលធាតុនៃចំណូលនិងចំណាយ ត្រូវបានកត់ត្រាលើកដំបូង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ចំណេញ ឬ ខាតលើស្ថានភាពរូបិយវត្ថុពិត

២៧ នៅក្នុងគ្រាមានអតិផរណា អង្គភាពមួយដែលកាន់កាប់ផ្នែកលើសនៃទ្រព្យសកម្មរូបិយវត្ថុលើបំណុលរូបិយវត្ថុ បាត់បង់អំណាចទិញ និងអង្គភាពមួយ

ជាមួយនឹងផ្នែកលើសនៃបំណុលរូបិយវត្ថុ លើទ្រព្យសកម្មរូបិយវត្ថុបង្កើន អំណោចទិញទៅតាមទំហំទឹកប្រាក់នៃទ្រព្យសកម្ម និងបំណុល មិនត្រូវបានភ្ជាប់ទៅនឹងកម្រិតតម្លៃទេ។ ចំណេញឬខាតលើស្ថានភាពរូបិយវត្ថុពិតនេះអាចត្រូវទទួលបានជាភាពខុសគ្នា ដែលកើតចេញពីការបង្ហាញឡើងវិញនៃទ្រព្យសកម្មមិនមែនរូបិយវត្ថុ មូលធនរបស់ម្ចាស់ និងធាតុទាំងឡាយនៅក្នុងរបាយការណ៍លទ្ធផលលម្អិត និងការកែសម្រួលនៃទ្រព្យសកម្ម និងបំណុលដែលជាប់នឹងសន្ទស្សន៍។ ចំណេញ ឬខាតអាច ត្រូវបានប៉ាន់ស្មានដោយការអនុវត្តការប្រែប្រួលសន្ទស្សន៍តម្លៃទូទៅ ធៀបនឹងមធ្យមភាគសម្រាប់គ្រានៃភាព ខុសគ្នារវាងទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុ ។

២៨ ចំណេញ ឬខាត លើស្ថានភាពរូបិយវត្ថុពិតត្រូវបានបញ្ចូលនៅក្នុងផលចំណេញ ឬខាត។ ការកែសម្រួលចំពោះ ទ្រព្យសកម្ម និងបំណុលទាំងនោះដែលភ្ជាប់ដោយកិច្ចព្រមព្រៀងធៀបនឹងការប្រែប្រួលតម្លៃដែលបានកើតឡើងដោយអនុលោមតាម កថាខណ្ឌ ១៣ ត្រូវបានកាត់កងទល់នឹងចំណេញ ឬខាត លើស្ថានភាពរូបិយវត្ថុពិត។ ធាតុចំណូល និងចំណាយផ្សេងទៀត ដូចជាចំណូលនិងចំណាយការប្រាក់ និងភាពខុសគ្នាពីអត្រាប្តូរប្រាក់ បរទេសដែលទាក់ទិននឹងមូលនិធិបានវិនិយោគនិងបានខ្ចី ក៏ត្រូវបានជាប់ទាក់ទិននឹងស្ថានភាពរូបិយវត្ថុពិត ។ ទោះបីជាធាតុបែបនេះត្រូវបានលាតត្រដាងបង្ហាញដាច់ដោយឡែក វាអាចមានប្រយោជន៍ប្រសិនបើធាតុទាំងនោះ ត្រូវបានដាក់បង្ហាញជាមួយនឹងចំណេញឬខាតលើស្ថានភាពរូបិយវត្ថុពិតនៅក្នុងរបាយការណ៍លទ្ធផលលម្អិត ។

របាយការណ៍ហិរញ្ញវត្ថុផ្អែកលើថ្លៃដើមបច្ចុប្បន្ន

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

២៩ ធាតុទាំងឡាយ ដែលបង្ហាញតាមថ្លៃដើមបច្ចុប្បន្នមិនត្រូវបានបង្ហាញឡើងវិញទេពីព្រោះពួកគេបានបង្ហាញរួច ហើយនៅក្នុងលក្ខខណ្ឌនៃឯកត្តាវាស់វែងបច្ចុប្បន្ន នៅចុងការិយបរិច្ឆេទរាយការណ៍។ ធាតុផ្សេងទៀតនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានបង្ហាញឡើងវិញដោយអនុលោមតាមកថាខណ្ឌ១១ ដល់ ២៥ ។

របាយការណ៍លទ្ធផលលម្អិត

៣០ របាយការណ៍លទ្ធផលលម្អិតផ្អែកលើថ្លៃបច្ចុប្បន្ន មុនការបង្ហាញឡើងវិញជាទូទៅរាយការណ៍ពីថ្លៃដើមបច្ចុប្បន្ននៅថ្ងៃដែលប្រតិបត្តិការកំពុងមាន ឬព្រឹត្តិការណ៍បានកើតឡើង។ ថ្លៃដើមលក់ និងរំលស់ត្រូវបានកត់ត្រាតាមថ្លៃដើមបច្ចុប្បន្ន នៅពេលដែលមានការប្រើប្រាស់ការលក់និង ចំណាយផ្សេងទៀតត្រូវបានកត់ត្រាតាមទឹកប្រាក់របស់ការលក់ និងចំណាយនោះនៅពេលដែលពួកគេកើតឡើង។ ដូច្នេះ ទឹកប្រាក់ទាំងអស់ ចាំបាច់ត្រូវតែបង្ហាញឡើងវិញទៅតាមឯកត្តាវាស់វែងរូបិយវត្ថុនៅចុងការិយបរិច្ឆេទរាយការណ៍ដោយការអនុវត្តសន្ទស្សន៍តម្លៃទូទៅ ។

ចំណេញឬខាតលើស្ថានភាពរូបិយវត្ថុពិត

៣១ ចំណេញ ឬខាត លើស្ថានភាពរូបិយវត្ថុពិត គឺត្រូវបានធ្វើគណនេយ្យកម្ម

ដោយអនុលោមតាមកថាខណ្ឌ ២៧ និង ២៨។

ពន្ធ

៣២ ការបង្ហាញឡើងវិញនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដានេះអាចនាំឱ្យកើតមានឡើងនូវ ភាពខុសគ្នារវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលមួយៗ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងមូលដ្ឋានពន្ធរបស់គេ។ ភាពខុសគ្នាទាំងនេះ ត្រូវបានធ្វើគណនេយ្យកម្ម ដោយអនុលោម តាម ស.គ.អ.ក ១២ *ពន្ធលើប្រាក់ចំណូល* ។

របាយការណ៍លំហូរសាច់ប្រាក់

៣៣ ស្តង់ដានេះ តម្រូវថាគ្រប់ធាតុទាំងអស់ នៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ត្រូវបានបញ្ចាក់នៅក្នុងលក្ខខណ្ឌនៃឯកតាវាស់វែងបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍ ។

តួរលេខស្របគ្នា

៣៤ តួរលេខស្របគ្នាសម្រាប់ការិយបរិច្ឆេទរាយការណ៍គ្រាមុន ថាតើតួរលេខទាំង នោះត្រូវបានផ្អែកលើវិធីសាស្ត្រ ថ្លៃដើមប្រវត្តិសាស្ត្រ ឬវិធីសាស្ត្រថ្លៃដើម បច្ចុប្បន្ន ត្រូវបានបង្ហាញឡើងវិញដោយប្រើសន្ទស្សន៍តម្លៃទូទៅ ដូច្នេះរបាយការណ៍ហិរញ្ញវត្ថុប្រៀបធៀបត្រូវបានដាក់បង្ហាញនៅក្នុងលក្ខខណ្ឌនៃឯកតាវាស់វែងបច្ចុប្បន្ន នៅចុងការិយបរិច្ឆេទរាយការណ៍។ សម្រាប់គោលបំណងនៃការបង្ហាញទឹកប្រាក់ប្រៀបធៀប ជារូបិយវត្ថុបង្ហាញ កថាខណ្ឌ

៤២(ខ) និង ៤៣ នៃ ស.គ.អ.ក ២១ អនុវត្ត។

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម

៣៥ ក្រុមហ៊ុនមេដែលរាយការណ៍ជារូបិយវត្ថុនៃសេដ្ឋកិច្ចដែលមានអតិផរណាហួសហេតុអាចមានក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានរាយការណ៍ ជារូបិយវត្ថុនៃសេដ្ឋកិច្ច ដែលមានអតិផរណាខ្ពស់ហួសហេតុផងដែរ។ របាយការណ៍ហិរញ្ញវត្ថុនៃក្រុមហ៊ុនបុត្រសម្ព័ន្ធបែបនេះ ចាំបាច់ត្រូវបានធ្វើការបង្ហាញឡើងវិញដោយប្រើសន្ទស្សន៍ តម្លៃទូទៅរបស់ប្រទេសដែលរូបិយវត្ថុរបស់ក្រុមហ៊ុននោះរាយការណ៍មុននឹងរូបិយវត្ថុទាំងនោះ ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមដែលបានចេញផ្សាយដោយក្រុមហ៊ុនមេ។ នៅពេលណាដែលក្រុមហ៊ុនបុត្រសម្ព័ន្ធ បែបនេះជាក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស របាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញឡើងវិញរបស់ក្រុមហ៊ុន នោះត្រូវប្រែសម្រួលតាមអត្រាបិទបញ្ជី ។ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមិនរាយការណ៍ ជារូបិយវត្ថុនៃសេដ្ឋកិច្ច ដែលមានអតិផរណាខ្ពស់ ហួសហេតុត្រូវបានដោះស្រាយតាម ស.គ.អ.ក ២១ ។

៣៦ ប្រសិនបើរបាយការណ៍ហិរញ្ញវត្ថុ ដែលមានចុងបញ្ចប់ការិយបរិច្ឆេទរាយការណ៍ខុសគ្នាត្រូវបានបង្រួមគ្រប់ធាតុទាំងអស់ មិនថាតើជាធាតុរូបិយវត្ថុឬមិនមែនរូបិយវត្ថុទេ ចាំបាច់ត្រូវតែបង្ហាញឡើងវិញទៅជាឯកតាវាស់វែងបច្ចុប្បន្ននៅថ្ងៃនៃរបាយការណ៍ហិរញ្ញវត្ថុរួម ។

ការជ្រើសរើស និង ការប្រើប្រាស់សន្ទស្សន៍តម្លៃទូទៅ

៣៧ ការបង្ហាញឡើងវិញនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដា នេះ តម្រូវឱ្យមានការប្រើប្រាស់សន្មស្សន៍តម្លៃទូទៅ ដែលឆ្លុះបញ្ចាំងពីការ ផ្លាស់ប្តូរអំណាចទិញទូទៅ ។ វាជាការប្រសើរដែលថា អង្គភាពទាំងអស់ ដែលរាយការណ៍ជារូបិយវត្ថុនៃសេដ្ឋកិច្ចដូចគ្នាប្រើប្រាស់សន្មស្សន៍ដូចគ្នា។

សេដ្ឋកិច្ចលែងមានអតិផរណាខ្ពស់ហួសហេតុ

៣៨ នៅពេលដែលសេដ្ឋកិច្ចឈប់មានអតិផរណាខ្ពស់ហួសហេតុ ហើយអង្គភាព មិនបន្តការរៀបចំនិងការបង្ហាញ របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំ ដោយអនុលោមតាមស្តង់ដានេះ អង្គភាពត្រូវចាត់ទុកទឹកប្រាក់ ដែល បានបញ្ចាក់ជាឯកត្តាវាស់វែងបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍គ្រា មុនជាមូលដ្ឋានសម្រាប់
តម្លៃយោងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុបន្តបន្ទាប់។

ការលាតត្រដាងព័ត៌មាន

៣៩ ការលាតត្រដាងព័ត៌មានខាងក្រោមត្រូវបានធ្វើឡើង៖

(ក) ហេតុការណ៍ដែលរបាយការណ៍ហិរញ្ញវត្ថុ និងតួរលេខស្របគ្នា សម្រាប់គ្រាមុនត្រូវបានបង្ហាញឡើងវិញ
សម្រាប់ការផ្លាស់ប្តូរអំណាច ទិញទូទៅនៃរូបិយវត្ថុមូលដ្ឋាន និងជាលទ្ធផលត្រូវបានបង្ហាញជា ឯកត្តា វាស់វែងបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍

(ខ) ថាតើរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានផ្អែកលើវិធីសាស្ត្រថ្លៃ

ប្រវត្តិសាស្ត្រ ឬ វិធីសាស្ត្រថ្លៃបច្ចុប្បន្ន និង

(គ) អត្តសញ្ញាណ និងកម្រិតនៃសន្ទស្សន៍តម្លៃនៅចុងការិយបរិច្ឆេទរាយការណ៍ និងការប្រែប្រួលសន្ទស្សន៍ ក្នុងកំឡុងការិយបរិច្ឆេទរាយការណ៍ត្រាមុន និងបច្ចុប្បន្ន។

៤០ ការលាតត្រដាងព័ត៌មានដែលបានតម្រូវដោយស្តង់ដានេះគឺចាំបាច់ត្រូវធ្វើឱ្យច្បាស់ពីមូលដ្ឋាននៃការដោះ ស្រាយផលប៉ះពាល់នៃអតិផរណានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការលាតត្រដាងព័ត៌មានក៏មានបំណងដើម្បីផ្តល់ព័ត៌មានចាំបាច់ផ្សេងទៀត ដើម្បីយល់ពីមូលដ្ឋាននិងទឹកប្រាក់ដែលកើតមាននោះ។

កាលបរិច្ឆេទប្រសិទ្ធិភាព

៤១ ស្តង់ដានេះចូលជាធរមានសម្រាប់របាយការណ៍ហិរញ្ញវត្ថុដែលគ្របដណ្តប់ការិយបរិច្ឆេទរាយការណ៍នៅថ្ងៃទី ឬ បន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩០។

ក្រុមប្រឹក្សាជាតិគណនេយ្យ

ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា

អាស័យដ្ឋាន: ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

អ៊ីម៉ែល: info@naccambodia.gov.kh | គេហទំព័រ: www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ